ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្តាល

សំណុំរឿងរដ្ឋប្បវេណី
លេខ ៧២៦
ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩
សាលក្រមរដ្ឋប្បវេណី
លេខ ៥៨ "គ"
ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៩

# តាមនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តកណ្តាល

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នាថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩ ។

## ចៅក្រម

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្តាល

## ក្រឡាបញ្ជី

លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្តាល

-ដើមចោទ [redacted] អាស័យដ្ឋាន [redacted] ។

ដោយមានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ ។

-សហចុងចម្លើយ

១-ឈ្មោះ [redacted] ម៉ានី ([redacted] សុម៉ានី) ភេទស្រី កើតឆ្នាំ១៩៧៥ អាស័យដ្ឋាន [redacted] ។

២-ឈ្មោះ [redacted] សុខ ភេទប្រុស កើតឆ្នាំ១៩៦២ អាស័យដ្ឋានភូមិ [redacted]

៣-ឈ្មោះ [redacted] សុផល្លី ភេទស្រី កើតឆ្នាំ១៩៦៨ អាស័យដ្ឋាន [redacted]

៤-ឈ្មោះ [redacted] ណារិន ភេទប្រុស កើតឆ្នាំ១៩៦៤ អាស័យដ្ឋាន [redacted] ។

៥-ឈ្មោះ [redacted] ស្រី ភេទស្រី កើតឆ្នាំ១៩៦៤ [redacted] ។

## អង្គហេតុ និងចំណុចវិវាទ

ក.ការទាមទាររបស់ដើមចោទ ៖

១. ប្រាក់ដើមចំនួន ២០.៨១៩,៨១ (ម្ភៃពាន់ប្រាំបីរយដប់ប្រាំបួន) ដុល្លារអាមេរិក។



Scanned with CamScanner

២. ការប្រាក់៖

២.១ គិតចាប់ពីថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៨ ដល់ថ្ងៃទូទាត់រួចក្នុងអត្រា ១៦,៨០% (ដប់ប្រាំមួយក្បៀសប៉ែតសិបភាគរយ) ក្នុងមួយឆ្នាំ លើប្រាក់ដើមចំនួន ៣.២៧៥,៩៧ (បីពាន់ពីររយចិតសិបប្រាំដុល្លារអាមេរិក ក្បៀសកៅសិបប្រាំពីរសេន) ។

២.២ គិតចាប់ពីថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៩ រហូតដល់ថ្ងៃទូទាត់ចប់សព្វគ្រប់ក្នុងអត្រាការប្រាក់១៨% (ដប់ប្រាំបីភាគរយ) ក្នុងមួយឆ្នាំ លើប្រាក់ដើមចំនួន ១៧.៥៥៣,៨៤ (ដប់ប្រាំពីរពាន់ប្រាំរយសែសិបបីដុល្លារអាមេរិក ក្បៀសប៉ែតសិបបួនសេន) ។

៣. ការប្រាក់ពិន័យ៖

៣.១ គិតចាប់ពីថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៨ រហូតដល់ថ្ងៃទូទាត់ចប់សព្វគ្រប់ក្នុងអត្រាស្មើនឹង២(ពីរ)ដង នៃអត្រាការប្រាក់ដែលមានចែងនៅក្នុងកិច្ចសន្យាខ្ចីបរិភោគ(រួម)លេខ ០៩៦/២០១៥ ឥ.ទ.អ.ល ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៥ លើប្រាក់ដើមចំនួន ៣.២៧៥,៩៧ (បីពាន់ពីររយចិតសិបប្រាំដុល្លារអាមេរិក ក្បៀសកៅសិបប្រាំពីរសេន) ។

៣.២ គិតចាប់ពីថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៧ រហូតដល់ថ្ងៃទូទាត់ចប់សព្វគ្រប់ក្នុងអត្រាស្មើនឹង២(ពីរ)ដងនៃអត្រាការប្រាក់ដែលមានចែងក្នុងកិច្ចសន្យាខ្ចីប្រាក់លេខ ០១៦០០០០០៩១៩០៩ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦ លើប្រាក់ដើមចំនួន ១៧.៥៤៣,៨៥ (ដប់ប្រាំពីរពាន់ប្រាំរយសែសិបបីដុល្លារអាមេរិកក្បៀសប៉ែតសិបបួនសេន) ។

៤. សេវាកម្មច្បាប់ ការខាតបង់ពេលវេលា និងសំណងជម្ងឺចិត្តចំនួន ៥.០០០ (ប្រាំពាន់ដុល្លារអាមេរិក )

៥. ប្រាក់ប្រដាប់ក្តី និងការចំណាយលើនីតិវិធីតុលាការជាបន្ទុករបស់សហចុងចម្លើយ។

៦. សាលក្រមនេះអាចអនុវត្តបណ្តោះអាសន្នបានត្រង់ចំនុចទី១,២,និង៣ ខាងលើ។

ខ. ការពន្យល់ត្រួសៗអំពីរឿងក្តី ៖

យោងតាមពាក្យបណ្តឹង ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] បានអះអាងថា ឈ្មោះ [redacted] ម៉ានី [redacted] សុម៉ានី) ឈ្មោះ [redacted] សុខ ឈ្មោះ [redacted] ផល្លី ឈ្មោះ [redacted] ណារិន និងឈ្មោះ [redacted] ស្រី បានខ្ចីប្រាក់ពី [redacted] ចំនួន ០២លើក ដែលមានទឹកប្រាកសរុបចំនួន ៣០.០០០ (សាមសិបពាន់ដុល្លារអាមេរិក) ដូចខាងក្រោម៖

**លើកទី១៖** តាមកិច្ចសន្យាខ្ចីបរិភោគលេខ ០៩៦/២០១៥ ឥ.ទ.អ.ល ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៥ មានទឹកប្រាក់សរុបចំនួន ១០.០០០ (ដប់ពាន់) ដុល្លារអាមេរិក តាមអត្រាការប្រាក់ ១៦,៨% ក្នុងមួយឆ្នាំ រយៈ



Scanned with CamScanner

ពេលខ្ចី ៦០ខែ ដោយធ្វើការរំលស់ប្រាក់ដើមថេរចំនួន ១៧២,៤១ (មួយរយចិតសិបពីរដុល្លារអាមេរិក កៀស សែសិបមួយសេន) និងសងការប្រាក់ជារៀងរាល់ខែ ចាប់ពីថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៥ ដល់ថ្ងៃទី១០ ខែមេសា ឆ្នាំ២០២០ ។

**លើកទី២៖** តាមកិច្ចសន្យាខ្ចីបរិភោគលេខ ០១៦០០០០០៩១៩០៩ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦ មានទឹកប្រាក់សរុបចំនួន ២០.០០០ (ម្ភៃពាន់) ដុល្លាររអាមេរិក តាមអត្រាការប្រាក់ ១៨% ក្នុងមួយឆ្នាំ រយៈពេលខ្ចី ៦០ខែ ដោយធ្វើការរំលស់ប្រាក់ដើមថេរចំនួន ៣៥០,៨៨ (បីរយហាសិបដុល្លារអាមេរិក កៀស ប៉ែតសិបប្រាំបីសេន) និងសងការប្រាក់ជារៀងរាល់ខែ ចាប់ពីថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៧ ដល់ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២១ ។

ក្នុងការអនុវត្តកាតព្វកិច្ច ចុងចម្លើយបានខកខានបង់ប្រាក់ដើម និងការប្រាក់ ជូនធនាគារជាច្រើនខែ ទោះបីមានការក្រើនរំលឹកជាច្រើនលើកច្រើនសារ ក៏ចុងចម្លើយនៅតែមិនអនុវត្តកាតព្វកិច្ចដដែល ។

**គ.ការអះអាងរបស់គូភាគី ៖**

-លោក [redacted] មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទបានថ្លែងការណ៍ថា៖ សុំរក្សាការទាមទារ ដូចក្នុងពាក្យបណ្តឹងចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩ និងការថ្លែងការក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ចុះថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ២០១៩ ទុកជាបានការដដែល ដោយហេតុថា ចុងចម្លើយបានខ្ចីប្រាក់ពីធនាគារចំនួន២លើកសរុប៣០.០០០ដុល្លារ ដោយលើកទី១ខ្ចីនៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៥ ចំនួន ១០.០០០ដុល្លារ អត្រាការប្រាក់១៦,៨ភាគរយ ក្នុងមួយឆ្នាំរយៈពេលខ្ចី៦០ខែ ដោយបង់រំលោះប្រាក់ដើមថេរចំនួន ១៧២,៤១ ដុល្លារ និងសងការប្រាក់ជារៀងរាល់ខែ គិតចាប់ពីថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៥ ដល់ថ្ងៃ ១០ ខែមេសា ឆ្នាំ២០២០ ។ លើកទី២ តាមកិច្ចសន្យាចុះថ្ងៃ២៨ ខែធ្នូ ឆ្នាំ២០១៦ ប្រាក់ដើម ២០.០០០ ដុល្លា អត្រា ១៨ ភាគរយ ក្នុងមួយឆ្នាំរយៈពេលខ្ចី ៦០ខែ ដោយរំលោះប្រាក់ដើមថេរចំនួន ៣៥០,៨៨ ដុល្លា និងសងការប្រាក់រាល់ខែគិតពីថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៧ ដល់ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២១។ ចុងចម្លើយបានអនុវត្តកាតព្វកិច្ចតែមួយរយៈនិងលែងអនុវត្តរហូតមក ទោះបីមានការជូនដំណឹងក៏ដោយដែលធ្វើឱ្យប៉ះពាល់ដល់សិទ្ធិនិងប្រយោជន៍របស់កូនក្តីយ៉ាងធ្ងន់ធ្ងរ។ សំណូមពរ សុំឱ្យតុលាការសម្រេចតាមការស្នើសុំខាងលើ ។

-សហចុងចម្លើយឈ្មោះ [redacted] ម៉ានី ([redacted] សុម៉ានី), [redacted] សុខ, [redacted] សុផល្លី, [redacted] ណារិន, [redacted] ស្រី (អវត្តមាន) ។

**៤.ចំណុចវិវាទ៖** តើការទាមទារដើមចោទត្រឹមត្រូវដែរឬទេ?

ដាក់បោះភស្តុតាងមាន៖

+តារាងសង្ខេបចុងក្រោយ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ចំនួន ០១ច្បាប់ ។

+កិច្ចសន្យាខ្ចីបរិភោគ(រួម)លេខ ០៩៦/២០១៥ ឥ.ទ.អ.ល ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៥ ចំនួន ០១ច្បាប់ ។

+ឧបសម្ព័ន្ធនៃកិច្ចសន្យាខ្ចីបរិភោគ(រួម)លេខ ០៩៦/២០១៥ ឥ.ទ.អ.ល ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៥ ចំនួន ០១ច្បាប់ ។

+តារាងកាលវិភាគសងប្រាក់ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៥ ចំនួន០១ច្បាប់ ។

+កិច្ចសន្យាខ្ចីប្រាក់លេខ ១៦០០០០០៩១៩០៩ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦ ចំនួន០១ច្បាប់។

+តារាងកាលវិភាគសងប្រាក់ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ ចំនួន០១ច្បាប់។

+កិច្ចសន្យាដាក់បញ្ចាំចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦ ចំនួន០១ច្បាប់។

+អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់ឈ្មោះ [redacted] ម៉ានី ([redacted] សុម៉ានី) ឈ្មោះ [redacted] សុខ ឈ្មោះ [redacted] សុផល្លី ឈ្មោះ [redacted] ណារិទ និងឈ្មោះ [redacted] ស្រី។

## សំអាងហេតុ

តាមលទ្ធផលនៃការសាកសួរ និងពិនិត្យភស្តុតាងក្នុងពេលទាញហេតុផលដោយផ្ទាល់មាត់ឃើញថា៖

-ពាក្យបណ្តឹង ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩ របស់ដើមចោទ [redacted] មានលក្ខណៈត្រឹមត្រូវ បញ្ជាក់ឲ្យឃើញថា សាលាដំបូងខេត្តកណ្តាលមានដែនសមត្ថកិច្ច ដើម្បីវិនិច្ឆ័យស្របច្បាប់នូវពាក្យបណ្តឹង ហើយចេញសាលក្រមបានតាមមាត្រា ៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

-លោក [redacted] មេធាវីតំណាងដោយអាណត្តិឲ្យដើមចោទ [redacted] ថ្លែងការណ៍ថា ចុងចម្លើយបានខ្ចីប្រាក់ពីធនាគារចំនួន២លើកសរុប៣០.០០០ដុល្លារ ដោយលើកទី១ខ្ចីនៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៥ ចំនួន១០.០០០ដុល្លារ អត្រាការប្រាក់១៦,៨ភាគរយ ក្នុងមួយឆ្នាំរយៈពេលខ្ចី៦០ខែ ដោយបង់រំលោះប្រាក់ដើមថេរចំនួន ១៧២,៤១ ដុល្លារ និងសងការប្រាក់ជារៀងរាល់ខែ គិតចាប់ពីថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៥ ដល់ថ្ងៃ១០ ខែមេសា ឆ្នាំ២០២០ ។ លើកទី២ តាមកិច្ចសន្យាចុះថ្ងៃ២៨ ខែធ្នូ ឆ្នាំ២០១៦ ប្រាក់ដើម ២០.០០០ ដុល្លារ អត្រា ១៨ ភាគរយ ក្នុងមួយឆ្នាំរយៈពេលខ្ចី ៦០ខែ ដោយរំលោះប្រាក់ដើមថេរចំនួន ៣៥០,៨៨ ដុល្លា និងសងការប្រាក់រាល់ខែគិតពីថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៧ ដល់ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២១។ ចុងចម្លើយបានអនុវត្តកាតព្វកិច្ចតែមួយរយៈនិងលែងអនុវត្តរហូតមក ទោះបីមានការជូនដំណឹងក៏

ដោយធ្វើឲ្យប៉ះពាល់ដល់សិទ្ធិនិងប្រយោជន៍របស់កូនក្តីយ៉ាងធ្ងន់ធ្ងរ។ សំណូមពរ សុំឲ្យតុលាការសម្រេច តាមការស្នើសុំខាងលើ ។

-សហចុងចម្លើយឈ្មោះ [redacted] ម៉ានី ([redacted] សុម៉ានី) ឈ្មោះ [redacted] សុខ ឈ្មោះ [redacted] សុផល្លី ឈ្មោះ [redacted] ណារិន និងឈ្មោះ [redacted] ស្រី ត្រូវបានតុលាការកោះហៅតាមដីកាកោះ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៩ រួចហើយ តែចុងចម្លើយបានអវត្តមាននាពេលទាញហេតុផលដោយផ្ទាល់មាត់ដោយគ្មានមូលហេតុ ហេតុនេះ តុលាការចាត់ទុកថាចុងចម្លើយបានសារភាព តាមសេចក្តីថ្លែងការណ៍របស់ដើមចោទដែលទាក់ទងនឹងអង្គហេតុខាងលើ ហើយតុលាការអាចចេញសាលក្រមកំបាំងមុខបាន យោងតាមមាត្រា ២០១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

-តាមភស្តុតាងជាឯកសារ កិច្ចសន្យាខ្ចីបរិភោគ (រួម) ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៥ និងកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦ រវាង [redacted] និងឈ្មោះ [redacted] ម៉ានី ([redacted] សុម៉ានី) ឈ្មោះ [redacted] សុខ ឈ្មោះ [redacted] សុផល្លី ឈ្មោះ [redacted] ណារិន និងឈ្មោះ [redacted] ស្រី បញ្ជាក់ថា សហចុងចម្លើយ ពិតជាបានរួមគ្នាខ្ចីប្រាក់ពី [redacted] ឬស្សីកែវ ចំនួន ០២លើក លើកទី១ ចំនួន ១០.០០០ (ដប់ពាន់) ដុល្លារអាមេរិក និងលើកទី២ ចំនួន ២០.០០០ (ម្ភៃពាន់) ដុល្លារអាមេរិក សរុប ៣០.០០០ (សាមសិបពាន់) ដុល្លារអាមេរិក ប្រាដកមែន ដោយបានដាក់បញ្ចាំនូវដីទំហំ ១៩៧៥.៧៨ម២=២២.៣០ម x៨៨.៦០ម មានពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីលំនៅដ្ឋានលេខ ១៤១ តំណាងឲ្យដី និងរាល់សំណង់ទាំងអស់ដែលស្ថិតនៅលើដីនេះ ស្ថិតនៅភូមិរាំងដេក ឃុំគគីរធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០០៧ និងដីទំហំ ១២៨៧ម២ មានប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ $C_6$ 0827 តំណាងឲ្យដី និងរាល់សំណង់ទាំងអស់ដែលស្ថិតនៅលើដីនេះ ស្ថិតនៅភូមិគគីរធំ ឃុំគគីរធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ១៩៩២ ចេញដោយអនុប្រធានការិយាល័យសុរិយោដី ខេត្តកណ្តាល តាមកិច្ចសន្យាដាក់បញ្ចាំ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦ (ចំនួន ០២ច្បាប់) ដើម្បីធានាបំណុល ។

-តាមតារាងសង្ខេបបំណុលចុងក្រោយ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ របស់ [redacted] បញ្ជាក់ថា សហចុងចម្លើយបានខកខានអនុវត្តកាតព្វកិច្ច បង់ប្រាក់ដើម និងការប្រាក់ជូនធនាគារលើកម្ចីលើកទី១ ចាប់ពីថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៨ រហូតមក នូវប្រាក់ដើមចំនួន ៣.២៧៥,៩៧ (បីពាន់ពីររយចិតសិបប្រាំដុល្លារអាមេរិក កៀសកៅសិបប្រាំពីសេន) និងកម្ចីលើកទី២ ចាប់ពីថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៧ រហូតមក នូវប្រាក់ដើមចំនួន ១៧.៥៤៣,៨៤ (ដប់ប្រាំពីរពាន់ប្រាំរយសែសិបបីដុល្លារអាមេរិក



Scanned with CamScanner

ក្បៀសប៉ែតសិបបួនសេន) សរុបប្រាក់ដើមដែលសល់ចុងចម្លើយនៅជំពាក់ទាំងពីរលើក មានចំនួនសរុប ២០.៨១៩,៨១ (ម្ភៃពាន់ប្រាំបីរយដប់ប្រាំបួនដុល្លារអាមេរិក ក្បៀសប៉ែតសិបមួយសេន) ។

-ក្នុងកម្ចីលើកទី១ គូភាគីបានព្រមព្រៀងគ្នាក្នុងអត្រាការប្រាក់ ១៦.៨០% ក្នុងមួយឆ្នាំ និងលើកទី២ គូភាគីបានព្រមព្រៀងគ្នាក្នុងអត្រាការប្រាក់ ១៨%ក្នុងមួយឆ្នាំ ដែលអត្រាការប្រាក់នេះគឺស្របតាមអត្រាការប្រាក់ដែលត្រូវបានកម្រិតតាមមាត្រា **៥៨៥** នៃក្រមរដ្ឋប្បវេណី និងប្រកាសលេខ ១០៨ ក.យ/ប្រ.ក/១១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ របស់ក្រសួងយុត្តិធម៌ ហេតុនេះគប្បីតុលាការពិចារណា ។

-ដើមចោទបានទាមទារការប្រាក់ពិន័យគិតចាប់ពីថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៨ រហូតដល់ថ្ងៃទូទាត់ចប់សព្វគ្រប់ ក្នុងអត្រាស្មើនឹង ០២ (ពីរ) ដង នៃអត្រាការប្រាក់ដែលមានចែងក្នុងកិច្ចសន្យាខ្ចីបរិភោគ (រួម) លេខ ០៩៦/២០១៥ ឥ.ទ.អ.ល ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៥ លើប្រាក់ដើមចំនួន ៣.២៧៥,៩៧ (បីពាន់ពីររយចិតសិបប្រាំដុល្លារអាមេរិក ក្បៀសកៅសិបប្រាំពីរសេន) និងការប្រាក់ពិន័យគិតចាប់ពីថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៧ រហូតដល់ថ្ងៃទូទាត់ចប់សព្វគ្រប់ ក្នុងអត្រាស្មើនឹង ០២ (ពីរ) ដង នៃអត្រាការប្រាក់ដែលមានចែងក្នុងកិច្ចសន្យាខ្ចីប្រាក់លេខ ០១៦០០០០០៩១៩០៩ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦ លើប្រាក់ដើមចំនួន ១៧.៥៤៣,៨៤ (ដប់ប្រាំពីរពាន់ប្រាំរយសែសិបបីដុល្លារអាមេរិក ក្បៀសប៉ែតសិបបួនសេន) ។ តុលាការយល់ឃើញថា ការទាមទារនេះគឺមានលក្ខណៈត្រឹមត្រូវ ដោយហេតុថា យោងតាមប្រការ ២.២ នៃកិច្ចសន្យាខ្ចីបរិភោគ (រួម) ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៥ និងប្រការ ២.២ នៃកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ២០១៦ គឺគូភាគីពិតជាបានព្រមព្រៀងគ្នាថា បើចុងចម្លើយមិនបានបង់ប្រាក់ទាន់ពេលវេលាតាមតារាងកាលវិភាគសងប្រាក់ ចុងចម្លើយត្រូវបង់ប្រាក់ពិន័យ ស្មើនឹង ០២ ដង នៃអត្រាការប្រាក់ក្នុងកិច្ចសន្យារហូតដល់ការប្រាក់ជំពាក់ត្រូវបានសងបញ្ចប់ ប្រាកដមែន គប្បីតុលាការពិចារណា ។

-ដើមចោទទាមទារឱ្យចុងចម្លើយសងថ្លៃសេវាច្បាប់ ការខាតបង់ពេលវេលា និងសំណងជម្ងឺចិត្តចំនួន ៥.០០០ (ប្រាំពាន់) ដុល្លារអាមេរិក គប្បីតុលាការពិនិត្យ និងសម្រេចតាមភាពសមរម្យជាក់ស្តែង ។

-ដើមចោទសុំអនុវត្តបណ្តោះអាសន្នត្រង់ចំណុចទី១ ប្រាក់ដើម ចំណុចទី២ ការប្រាក់ និងចំណុចទី៣ ប្រាក់ពិន័យ ឃើញថាមានលក្ខណៈត្រឹមត្រូវ ដោយហេតុថា មានភស្តុតាងច្បាស់លាស់ដែលបញ្ជាក់ពីការខ្ចីប្រាក់ ហើយការសម្រេចនេះជាការសម្រេចអំពីការទាមទារសិទ្ធិលើទ្រព្យសម្បត្តិ ដែលអាចឱ្យតុលាការធ្វើការសម្រេចប្រកាសសាលក្រមមានអានុភាពអនុវត្តបណ្តោះអាសន្ន តាមបញ្ញត្តិមាត្រា ១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។



Scanned with CamScanner

-ប្រាក់ប្រដាប់ក្តីយោងតាមបញ្ញត្តិមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី គប្បីជាបន្ទុករបស់សហចុងចម្លើយ ។

## សេចក្តីសម្រេចបញ្ចប់

១-បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ [redacted] ម៉ានី ([redacted] សុម៉ានី) ឈ្មោះ [redacted] សុខ ឈ្មោះ [redacted] សុផល្លី ឈ្មោះ [redacted] ណារិន និងឈ្មោះ [redacted] ស្រី រួមគ្នាសងប្រាក់ដើមចំនួន ២០.៨១៩,៨១ (ម្ភៃពាន់ប្រាំបីរយដប់ប្រាំបួនដុល្លារអាមេរិក ក្បៀសប៉ែតសិបមួយសេន) ទៅឱ្យដើមចោទ [redacted] តំណាងស្របច្បាប់ដោយលោក [redacted] រដ្ឋា (តំណាងប្រធានក្រុមប្រឹក្សាភិបាល) លោក [redacted] ។

២-បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ [redacted] ម៉ានី ([redacted] សុម៉ានី) ឈ្មោះ [redacted] សុខ ឈ្មោះ [redacted] សុផល្លី ឈ្មោះ [redacted] ណារិន និងឈ្មោះ [redacted] ស្រី រួមគ្នាសងការប្រាក់ទៅឱ្យដើមចោទ [redacted] តំណាងស្របច្បាប់ដោយលោក [redacted] រដ្ឋា (តំណាងប្រធានក្រុមប្រឹក្សាភិបាល) លោក [redacted] ដូចខាងក្រោម៖

ក-ការប្រាក់គិតចាប់ពីថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៨ ដល់ថ្ងៃទូទាត់រួចក្នុងអត្រា ១៦,៨០% (ដប់ប្រាំ មួយក្បៀសប៉ែតសិបភាគរយ) ក្នុងមួយឆ្នាំ លើប្រាក់ដើមចំនួន ៣.២៧៥,៩៧ (បីពាន់ពីររយចិតសិបប្រាំដុល្លារអាមេរិក ក្បៀសកៅសិបប្រាំពីរសេន) ។

ខ-ការប្រាក់គិតចាប់ពីថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៩ រហូតដល់ថ្ងៃទូទាត់ចប់សព្វគ្រប់ក្នុងអត្រាការប្រាក់១៨% (ដប់ប្រាំបីភាគរយ) ក្នុងមួយឆ្នាំ លើប្រាក់ដើមចំនួន ១៧.៥៥៣,៨៤ (ដប់ប្រាំពីរពាន់ប្រាំរយសែសិបបីដុល្លារអាមេរិក ក្បៀសប៉ែតសិបបួនសេន) ។

៣-បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ [redacted] ម៉ានី ([redacted] សុម៉ានី) ឈ្មោះ [redacted] សុខ ឈ្មោះ [redacted] សុផល្លី ឈ្មោះ [redacted] ណារិន និងឈ្មោះ [redacted] ស្រី រួមគ្នាសងការប្រាក់ពិន័យទៅឱ្យដើមចោទ [redacted] តំណាងស្របច្បាប់ដោយលោក [redacted] រដ្ឋា (តំណាងប្រធានក្រុមប្រឹក្សាភិបាល) លោក [redacted] ដូចខាងក្រោម៖

ក-ការប្រាក់ពិន័យគិតចាប់ពីថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៨ រហូតដល់ថ្ងៃទូទាត់ចប់សព្វគ្រប់ក្នុងអត្រាស្មើនឹង២(ពីរ)ដង នៃអត្រាការប្រាក់ដែលមានចែងនៅក្នុងកិច្ចសន្យាខ្ចីបរិភោគ(រួម)លេខ



Scanned with CamScanner

០៩៦/២០១៥ ត.ទ.អ.ល ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៥ លើប្រាក់ដើមចំនួន ៣.២៧៥,៩៧ (បីពាន់ពីររយចិតសិបប្រាំដុល្លារអាមេរិក កៀសកៅសិបប្រាំពីរសេន) ។

ខ-ការប្រាក់ពិន័យគិតចាប់ពីថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៧ រហូតដល់ថ្ងៃទូទាត់ចប់សព្វគ្រប់ ក្នុងអត្រាស្មើនឹង ០២ (ពីរ) ដង នៃអត្រាការប្រាក់ដែលមានចែងក្នុងកិច្ចសន្យាខ្ចីប្រាក់លេខ ០១៦០០០០០៩១៩០៩ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦ លើប្រាក់ដើមចំនួន ១៧.៥៤៣,៨៥ (ដប់ប្រាំពីរពាន់ប្រាំរយសែសិបបីដុល្លារអាមេរិកកៀសប៉ែតសិបប្រាំសេន) ។

៤-បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ [redacted] ម៉ានី ([redacted] សុម៉ានី) ឈ្មោះ [redacted] សុខ ឈ្មោះ [redacted] សុផល្លី ឈ្មោះ [redacted] ណារិន និងឈ្មោះ [redacted] ស្រី រួមគ្នាបង់ប្រាក់សេវាកម្មច្បាប់ ការខាតបង់ពេលវេលា និងសំណងជម្ងឺចិត្តចំនួន ៦.០០០.០០០ (ប្រាំមួយលាន) រៀល ទៅឱ្យដើមចោទ [redacted] តំណាងស្របច្បាប់ដោយលោក [redacted] រដ្ឋា (តំណាងប្រធានក្រុមប្រឹក្សាភិបាល) លោក [redacted] ។

៥-សាលក្រមនេះអាចអនុវត្តជាបណ្ដោះអាសន្នបានត្រង់ចំណុច ទី១ ទី២ និងទី៣ នៃសេចក្ដីសម្រេចបញ្ចប់ខាងលើ ។

៦-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់សហចុងចម្លើយឈ្មោះ [redacted] ម៉ានី [redacted] សុម៉ានី) ឈ្មោះ [redacted] សុខ ឈ្មោះ [redacted] សុផល្លី ឈ្មោះ [redacted] ណារិន និងឈ្មោះ [redacted] ស្រី ។

សាលក្រមនេះប្រកាសជាសាធារណៈនៅថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៩ ។

**ចៅក្រម**

ហត្ថលេខា និងត្រា [redacted]

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃព្រហស្បតិ៍ ១១កើត ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

កណ្ដាល,ថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៩

**បានឃើញ**

**ចៅក្រម**

[redacted]

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner